ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ ៧៧៩ អក
ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩
សាលក្រមព្រហ្មទណ្ឌលេខ:០០៣ "ឆ" ក្រ
ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ០៩ និង ០០នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចខាងក្រោម ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

### មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

លោកមេធាវី [redacted] និងលោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សំណាន និងឈ្មោះ [redacted] ជម។

-ដើម្បីធ្វើការជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៧៧៩ អក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទដូចខាងក្រោម ៖

១-ឈ្មោះ [redacted] សុភ័ក្ត្រ ភេទប្រុស អាយុ ៣៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កម្មករសំណង់ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] សាអែម (ស) ម្ដាយឈ្មោះ [redacted] សារ៉េត (ស) ប្រពន្ធឈ្មោះ [redacted] សំអឿន មានកូន ០៣ នាក់ ជានីតិជន ទោសពីមុន គ្មាន។

២-ឈ្មោះ [redacted] ផាតសោភ័ណ្ឌ ភេទប្រុស អាយុ ២៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាងផ្សារដែក មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្ដាល និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ចាន់ផាត(រ) ម្ដាយឈ្មោះ [redacted] គីមហ៊ាង (រ) ប្រពន្ធឈ្មោះ [redacted] ជីវ៉ា ជានីតិជន ទោសពីមុន គ្មាន ។

៣-ឈ្មោះ [redacted] សំអឿន ភេទស្រី អាយុ ២៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កម្មករសំណង់ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្ដាល និងទីលំនៅបច្ចុប្បន្ន



បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ខេត្តកណ្ដាល ថ្ងៃទី...១៦...ខែ...មិថុនា...ឆ្នាំ២០២០
ក្រឡាបញ្ជី

[redacted]

នៅភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] អិត (ស) ម្ដាយឈ្មោះ[redacted]តាប់ (រ) ប្ដីឈ្មោះ [redacted]សុភ័ក្ត្រ(រ) មានកូន០៣ នាក់ ទោសពីមុន គ្មាន។

៤-ឈ្មោះ [redacted]**សំណាន** ភេទប្រុស អាយុ ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កម្មករសំណង់ មានទីកន្លែងកំណើតនៅ[redacted]ខេត្តកណ្ដាល និងទីលំនៅបច្ចុប្បន្ននៅ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted](រ) ម្ដាយឈ្មោះ [redacted] **ផល្លី** (រ) នៅលីវ ជាអនីតិជន ទោសពីមុន **គ្មាន** ។

ជាប់ចោទពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន(មិនរាងចាល)** ប្រព្រឹត្តនៅ ភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **៤០ ,៤៥ កថាខណ្ឌ២** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៥-ឈ្មោះ [redacted] **ជេម** ភេទប្រុស អាយុ ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ បើកឡានដឹកទឹកកក មានទីកន្លែងកំណើតនៅ[redacted]ខេត្តកណ្ដាល និងទីលំនៅបច្ចុប្បន្ននៅ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted]វិចិត្រ (រ) ម្ដាយឈ្មោះ[redacted]**ផារី** (រ) នៅលីវ ជាអនីតិជន ទោសពីមុន គ្មាន ។

ជាប់ចោទពីបទ៖ **ប្រើប្រាស់ដោយខុសច្បាប់នូវសារជាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **៤៥ កថាខណ្ឌ១** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

-**បានឃើញ** របាយការណ៍សរុបលេខ **០៦០** របក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០១៩ របស់អធិការដ្ឋាននគរបាលស្រុកស្អាង ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៖ **៥៩៧** ដកសស ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ៖ **៦២៨** ដកសព ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-**បានឃើញ** ដីកាដំណោះស្រាយលេខ៖ **៧១៦** ដកដស ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង ១១ និង៣០ នាទី មានករណី ជួញដូរដោយខុសច្បាប់នូវសារជាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារជាតុញៀន (មិនរៀងចាល) ប្រព្រឹត្តនៅចំនុចភូមិលេខ១ ឃុំស្វាយរលំ ស្រុងស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង ១១ និង ៣០ នាទីដែលបង្កឡើងដោយឈ្មោះ[redacted]សុភ័ក្ត្រ និងប្រពន្ធឈ្មោះ[redacted] សំអឿន ហៅ វី បានរកស៊ីទិញ លក់ ថ្នាំញៀន ប្រភេទម៉ាទឹកកកយ៉ាងសកម្មនៅក្នុងភូមិ ឃុំរបស់ខ្លួន។ បន្ទាប់ពីបានទទួលព័ត៌មាននេះកម្លាំងសមត្ថកិច្ចបានចុះបង្ក្រាប ឈានដល់ការឃាត់ខ្លួនបានជនសង្ស័យដែលពាកព័ន្ធផ្សេងទៀតរួមមាន៖ ឈ្មោះ[redacted] ផាតសោភ័ណ្ឌ, ឈ្មោះ [redacted] សំណាន និងឈ្មោះ [redacted] ជេម រួមទាំងបានឆែកឆេររកថ្នាំញៀនចំនួន ១៥ កញ្ចប់ (២ធំ តូច១៣កញ្ចប់) និងសម្ភារៈសម្រាប់វេចខ្ចប់គ្រឿងញៀនមួយចំនួនទៀត បញ្ជូនមកអធិការនគរបាលស្រុកស្អាងតែម្ដង។



បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ខេត្តកណ្ដាល ថ្ងៃទី....... ខែ....... ឆ្នាំ២០២០
ក្រឡាបញ្ជី
[redacted]

## **នាពេលសួរចម្លើយ**

១-ជនជាប់ចោទឈ្មោះ [redacted]សុភ័ក្រ្ត បានឆ្លើយថា: កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល១១ ជាង ខ្លួន និងប្រពន្ធឈ្មោះ [redacted]សំអឿន កំពុងហៅភ្ញៀវការខ្លួនឯង នៅផ្ទះដែលពួកម៉ាកខ្ញុំជួលនៅស្ថិតនៅក្នុងភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ពេលនោះខ្លួនបានឃើញឈ្មោះ ពៅ ភេទប្រុស អាយុប្រហែល២១ ឆ្នាំ ឈ្មោះ ម៉ៅ ភេទប្រុស និងម្នាក់ទៀតមិនស្គាល់ឈ្មោះ។ អ្នកទាំងបីនាក់នោះ បានមកឈរអោរនិង លក់គ្រឿងញៀន នៅពីមុខផ្ទះជួលរបស់ខ្លួន ចំណែកឯឈ្មោះ **សោភ័ណ** និងឈ្មោះ[redacted] **ណារ** ហៅញាញ់ បានឈរនៅក្បែរដើមអំពិលទឹក ចម្ងាយប្រហែល១០០ ម៉ែត្រ តែខ្លួនមិនដឹងពួកវាឈរធ្វើអ្វីទេ។ ស្រាប់តែពេលនោះឃើញមានសមត្ថកិច្ច មកដល់ក៏បានឃាត់រូបខ្លួន ហើយបានធ្វើការឆែកឆេរខ្លួន និងប្រពន្ធ ពុំបានរកឃើញមានថ្នាំញៀននោះទេ ហើយបាននាំពួកខ្លួនទៅឆែកឆេរ នៅក្នុងបន្ទប់ជួលខ្លួនបានរកឃើញមានថ្នាំញៀនម៉ាទឹកកមួយកញ្ចប់ធំ និងឧបករណ៍ប្រើប្រាស់វេចខ្ចប់មួយចំនួន ព្រមទាំងជញ្ជីងសម្រាប់ថ្លឹងថ្នាំញៀនមួយទៀតផង ដោយសមត្ថកិច្ចចូលទៅឆែកឆេរក្នុងផ្ទះខ្លួន ចំណែកឯខ្លួនបានក្រាបនៅមុខផ្ទះក្រៅរបង ហើយថ្នាំញៀនដែលសមត្ថកិច្ចបានឆែកឆេររកឃើញនៅក្នុងផ្ទះនោះពុំមែនជារបស់ខ្លួន និងប្រពន្ធឡើយ ព្រោះផ្ទះជួលនោះខ្លួននិងប្រពន្ធបានចាក់សោរចោលជិតរយៈពេលមួយខែហើយ មិនដឹងថាអ្នកណាចូលហែកជញ្ជាំងក្តារពុកៗ ធ្វើសកម្មភាពនោះទេ។ បន្ទាប់មកសមត្ថកិច្ចបានរកឃើញមានថ្នាំញៀននៅក្នុងចំការស្លុំ នៅចំមុខផ្ទះខ្លួនបានជាច្រើនកញ្ចប់ មិនដឹងជានណាបោះចោលនោះទេ។ កន្លងមកខ្ញុំធ្លាប់បានប្រើប្រាស់គ្រឿងញៀន ជាមួយប្រពន្ធឈ្មោះ [redacted]សំអឿន បានចំនួន០២ លើកមកហើយ ដោយទិញមួយលើកចំនួន ០១ កញ្ចប់ធំ តម្លៃ៨០,០០០រៀល ដើម្បីយកមកប្រើប្រាស់ជាមួយប្រពន្ធ និងចែករំលែកឲ្យគេជក់ខ្លះ ដោយយកលុយពីគេជក់ម្តងចំនួន ១៥,០០០រៀល ជក់នៅផ្ទះជួលចាស់ តែសកម្មភាពនេះ ខ្លួន និងប្រពន្ធ ឈប់ប្រព្រឹត្ត បានប្រហែលមួយខែទៅហើយ ដោយរវល់ហៅភ្ញៀវការ និងខ្លាចសមត្ថកិច្ចចាប់ខ្លួន។

២-ជនជាប់ចោទឈ្មោះ[redacted] **សំអឿន** បានឆ្លើយថា: ប្តីរបស់ខ្លួនឈ្មោះ[redacted]សុភ័ក្រ គាត់ពីមុនធ្លាប់ជួញដូរគ្រឿងញៀន តែឥលូវគាត់ឈប់លក់គ្រឿងញៀនហើយ ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀន។ កន្លងមកខ្លួនធ្លាប់ទិញគ្រឿងញៀនពីឈ្មោះ វី ភេទប្រុស អាយុ ២៧ ឆ្នាំ យកមករំលែកជាកញ្ចប់តូចៗ ដើម្បីលក់បន្ត ដោយឈ្មោះ វី បានប្រើឲ្យឈ្មោះ[redacted] ផាតសោភ័ណ្ឌ យកមកឲ្យខ្លួន។ លុះដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ ខ្លួនបានទៅហៅភ្ញៀវការនៅភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល។ ពេលទៅដល់ ស្រាប់តែឃើញសមត្ថកិច្ចឃាត់ប្តីរបស់ខ្លួនឈ្មោះ [redacted] សុភ័ក្រ្ត ខ្លួនក៏បានចូលទៅសួរនាំ ស្រាប់តែសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ បន្ទាប់មកសមត្ថកិច្ចបានចុះទៅឆែកឆេរនៅផ្ទះរបស់ខ្លួនឃើញគ្រឿងញៀនចំនួន ០១ កញ្ចប់ធំ និងឧបករណ៍ប្រើប្រាស់វេចខ្ចប់មួយចំនួន ហើយក៏បន្តរុករកឃើញថ្នាំញៀនចំនួន ១០ កញ្ចប់ទៀត។

៣-ជនជាប់ចោទឈ្មោះ [redacted] **ផាតសោភ័ណ្ឌ** បានឆ្លើយថា: កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ ប្រហែលម៉ោង១២ ថ្ងៃត្រង់ ខ្លួនបានចេញពីធ្វើការវិញ ខ្លួនបានទៅទិញថ្នាំពីឈ្មោះ វៃ ហៅ វី ភេទប្រុស អាយុប្រហែល ២០ ឆ្នាំជាង នៅភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល បានចំនួន០៤ កញ្ចប់តូច តម្លៃ ៦០,០០០ រៀល ដើម្បីយកប្រើប្រាស់(ជក់) ជាមួយឈ្មោះ[redacted] ជេម និងពីរនាក់ទៀតមិនស្គាល់ឈ្មោះ លុយ៦០,០០០រៀល ទៀត ខ្លួនបានមកពីការរៃលុយគ្នាដោយឈ្មោះ[redacted]ជេម ឲ្យខ្លួន



បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ខេត្តកណ្តាល ថ្ងៃទី...[illegible]...ខែ...[illegible]...ឆ្នាំ២០២០...
ក្រឡាបញ្ជី

[redacted]

Scanned with CamScanner

បាន១០,០០០ រៀល ហើយគេមិនបានទិញគ្រឿងញៀនជាមួយខ្លួនទេ។ នៅពេលដែលខ្លួនទិញថ្នាំញៀនពីឈ្មោះ វីត ហៅ វី បានហើយខ្លួនបានត្រលប់មកផ្ទះវិញ បានពាក់កណ្តាលផ្លូវក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនបានតែម្តង។ នៅពេលដែលសមត្ថកិច្ចឃាត់ខ្លួនបានដកហូតយកគ្រឿងញៀន ចំនួន០៤ កញ្ចប់តូចក្រៅពីនោះពុំមានអ្វីទៀតទេ។ ខ្លួនធ្លាប់បានប្រើប្រាស់គ្រឿងញៀនចំនួន៥ ខែមកហើយ។

៤-ជនជាប់ចោទឈ្មោះ [redacted] **សំណាន** បានឆ្លើយថាៈ កន្លងមកខ្លួនធ្លាប់បានជាប់ពន្ធនាគាររយៈពេល ០១ឆ្នាំ ០១ខែ ពីបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅពន្ធនាគារខេត្តកណ្តាល។ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល១១ ថ្ងៃត្រង់ ខ្លួនបានដេកលើអង្រឹងនៅផ្ទះចាប់ហួយ ស្រាប់តែសមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្តង ហើយធ្វើការឆែកឆេរលើខ្លួន ពុំបានរកឃើញថ្នាំញៀនឡើយ ហើយក៏មិនបានដកហូតអ្វីពីខ្លួននោះទេ។ ខ្លួនធ្លាប់បានប្រើប្រាស់ថ្នាំញៀនរយៈពេលជាង ០២ ឆ្នាំមកហើយ ។ ថ្នាំដែលខ្លួនបានទិញមកប្រើប្រាស់នោះទិញពីឈ្មោះ[redacted] សុភ័ក្រ្ត ភេទប្រុស នៅភូមិលេខ១ ស្រុកស្អាង ខេត្តកណ្តាល ដោយទិញម្តង ០១ កញ្ចប់ តម្លៃ១៥,០០០ រៀល ទៅ ២០,០០០ រៀល។

៥-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ជេម** បានឆ្លើយថាៈ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង១០ និង៣០ នាទីព្រឹក ខ្លួនបានជិះកង់ចេញពីផ្ទះរបស់ខ្លួនតែម្នាក់ឯងនៅភូមិព្រែកសំរោង២ សង្កាត់ព្រែកសំរោង២ ទៅរកទិញថ្នាំញៀន ដើម្បីយកមកប្រើប្រាស់(ជក់) លុះទៅដល់ភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ក៏បានជួបនិងឈ្មោះ **ភ័ណ្ឌ** ហើយឈ្មោះ **ភ័ណ្ឌ** ក៏បានបបួលខ្លួនថាចូលលុយគ្នាទិញថ្នាំមកជក់ ខ្លួនក៏បានឲ្យលុយទៅឈ្មោះ ភ័ណ្ឌ ១ម៉ឺនរៀល ដើម្បីឲ្យគាត់ទៅទិញថ្នាំញៀនជាមួយគ្នា ហើយឈ្មោះ **ភ័ណ្ឌ** ក៏បានទៅទិញថ្នាំញៀនតែម្នាក់ឯង ចំណែកឯខ្លួនរង់ចាំឈ្មោះ **ភ័ណ្ឌ** នៅមុខរោងចក្រ ប៉ាត់តេ ភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល បានមួយសន្ទុះក៏បានឃើញសមត្ថកិច្ចចាប់បណ្តើរឈ្មោះ **ភ័ណ្ឌ** មករកខ្លួនដែលកំពុងរង់ចាំ ហើយសមត្ថកិច្ចបានចាប់រូបខ្លួនថែមមួយនាក់ទៀត ដោយធ្វើការឆែកឆេរមកលើរូបខ្លួនតែរកពុំឃើញមានថ្នាំញៀននោះទេ។ នៅពេលដែលសមត្ថកិច្ចចាប់រូបខ្លួននោះ គឺខ្លួននៅតែម្នាក់ឯងនោះទេ ពុំមានបក្សពួកផ្សេងទៀតនៅជាមួយខ្លួនទេ។ ខ្លួនពុំបានដឹងថាមានឈ្មោះ ភ័ណ្ឌ ទៅទិញថ្នាំញៀនប៉ុន្មានកញ្ចប់ទេ ព្រោះក្រោយពីឈ្មោះ ភ័ណ្ឌ ទិញថ្នាំញៀនរួចហើយ គាត់ពុំទាន់បានមកជួបខ្លួនផង ក៏ត្រូវបានសមត្ថកិច្ចចាប់បានខ្លួនគាត់បានតែម្តង។ នៅពេលសមត្ថកិច្ចចាប់ខ្លួនបានគឺមិនបានដកហូតសម្ភារៈអ្វីពីខ្លួនទេ។ ខ្លួនធ្លាប់បានប្រើប្រាស់គ្រឿងញៀនរយៈពេលប្រហែល១ឆ្នាំហើយមួយខែខ្លួនប្រើប្រាស់១ដង ខ្លួនពុំដែលធ្វើការជួញដូរថ្នាំញៀននោះទេ។

៦-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការ តំណាងអយ្យយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **សុភ័ក្រ្ត** ,ឈ្មោះ [redacted] **ផាតសោភ័ណ្ឌ** , ឈ្មោះ [redacted] **សំអឿន**, ឈ្មោះ [redacted] **សំណាន** និងឈ្មោះ [redacted] **ជេម** ពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់មែន ហេតុនេះតំណាងអយ្យការស្នើសុំរក្សាបទចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ **៦២៨** ដកសព ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ ទុកដដែល និងស្នើសុំតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

៧-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ៖ ស្នើសុំឲ្យតុលាការធ្វើការសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន ព្រោះកូនក្តីខ្លួនជាអនីតិជន មានកម្រិតវប្បធម៌តិចតួច ខ្វះការពិចារណាបានវែងឆ្ងាយ តាមមាត្រា **១៦០** នៃក្រមព្រហ្មទណ្ឌ។

ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ខេត្តកណ្តាល ថ្ងៃទី 16 ... ឆ្នាំ២០២០
ក្រឡាបញ្ជី
[redacted]



Scanned with CamScanner

៨-សម្តីចុងក្រោយរបស់ជនជាប់ចោទ ៖ សុំឲ្យតុលាការបន្ធូរបន្ថយទោស ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិ

ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាងនានា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង ១១ និង៣០ នាទី មានករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន (មិនរៀងចាល) ប្រព្រឹត្តនៅចំនុចភូមិលេខ១ ឃុំស្វាយរលំ ស្រុងស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០១៩ វេលាម៉ោង ១១ និង ៣០ នាទីដែលបង្ករឡើងដោយជនសង្ស័យឈ្មោះ [redacted] សុភ័ក្ត្រ និងប្រពន្ធឈ្មោះ [redacted] សំអឿន ហៅ វី បានរកស៊ីទិញ លក់ ថ្នាំញៀន ប្រភេទម៉ាទឹកកកយ៉ាងសកម្មនៅក្នុងភូមិ ឃុំរបស់ខ្លួន។ បន្ទាប់ពីបានទទួលព័ត៌មាននេះកម្លាំងសមត្ថកិច្ចបានចុះបង្ក្រាប ឈានដល់ការឃាត់ខ្លួនបានជនសង្ស័យដែលពាក់ព័ន្ធផ្សេងទៀតរួមមាន៖ ឈ្មោះ [redacted] ផាតសោភ័ណ្ឌ, ឈ្មោះ [redacted] សំណាន និងឈ្មោះ [redacted] ដេម រួមទាំងបានឆែកឆេររកថ្នាំញៀនចំនួន ១៥ កញ្ចប់ (២ធំ តូច១៣ កញ្ចប់) និងសម្ភារៈសម្រាប់វេចខ្ចប់គ្រឿងញៀនមួយចំនួនទៀត បញ្ជូនមកអធិការនគរបាលស្រុកស្អាងតែម្តង។

២-ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្ត្រ បានឆ្លើយថាៈ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល១១ ជាង ខ្លួន និងប្រពន្ធឈ្មោះ [redacted] សំអឿន កំពុងហៅភ្ញៀវការខ្លួនឯង នៅផ្ទះដែលពួកម៉ាកខ្ញុំជួលនៅស្ថិតនៅក្នុងភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ពេលនោះខ្លួនបានឃើញឈ្មោះ ពៅ ភេទប្រុស អាយុប្រហែល២១ ឆ្នាំ ឈ្មោះ ម៉ៅ ភេទប្រុស និងម្នាក់ទៀតមិនស្គាល់ឈ្មោះ។ អ្នកទាំងបីនាក់នោះ បានមកឈររោនិង លក់គ្រឿងញៀន នៅពីមុខផ្ទះជួលរបស់ខ្លួន ចំណែកឯឈ្មោះ **សោភ័ណ** និងឈ្មោះ [redacted] **ណាន** ហៅញាញ់ បានឈរនៅក្បែរដើមអំពិលទឹក ចម្ងាយប្រហែល១០០ ម៉ែត្រ តែខ្លួនមិនដឹងពួកវាឈរធ្វើអ្វីទេ។ ស្រាប់តែពេលនោះឃើញមានសមត្ថកិច្ច មកដល់ក៏បានឃាត់រូបខ្លួន ហើយបានធ្វើការឆែកឆេរខ្លួន និងប្រពន្ធ ពុំបានរកឃើញមានថ្នាំញៀននោះទេ ហើយបាននាំពួកខ្លួនទៅឆែកឆេរ នៅក្នុងបន្ទប់ជួលខ្លួនបានរកឃើញមានថ្នាំញៀនម៉ាទឹកកកមួយកញ្ចប់ធំ និងឧបករណ៍ប្រើប្រាស់វេចខ្ចប់មួយចំនួន ព្រមទាំងជញ្ជីងសម្រាប់ថ្លឹងថ្នាំញៀនមួយទៀតផង ដោយសមត្ថកិច្ចចូលទៅឆែកឆេរក្នុងផ្ទះខ្លួន ចំណែកឯខ្លួនបានក្រាបនៅមុខផ្ទះក្រៅរបង ហើយថ្នាំញៀនដែលសមត្ថកិច្ចបានឆែកឆេររកឃើញនៅក្នុងផ្ទះនោះពុំមែនជារបស់ខ្លួន និងប្រពន្ធឡើយ ព្រោះផ្ទះជួលនោះខ្លួននិងប្រពន្ធបានចាក់សោរចោលជិតរយៈពេលមួយខែហើយ មិនដឹងថាអ្នកណាចូលហែកជញ្ជាំងក្តារពុកៗ ធ្វើសកម្មភាពនោះទេ។ បន្ទាប់មកសមត្ថកិច្ចបានរកឃើញមានថ្នាំញៀននៅក្នុងចំការស្ពៃ នៅចំមុខផ្ទះខ្លួនបានជាច្រើនកញ្ចប់ មិនដឹងជានណាបោះចោលនោះទេ។ កន្លងមកខ្ញុំធ្លាប់បានប្រើប្រាស់គ្រឿងញៀន ជាមួយប្រពន្ធឈ្មោះ [redacted] សំអឿន បានចំនួន០២ លើកមកហើយ ដោយទិញមួយលើកចំនួន ០១ កញ្ចប់ធំ តម្លៃ៨០,០០០រៀល ដើម្បីយកមកប្រើប្រាស់ជាមួយប្រពន្ធ និងចែករំលែកឲ្យគេជក់ខ្លះ ដោយយកលុយពីគេជក់ម្តងចំនួន ១៥,០០០រៀល ជក់នៅផ្ទះជួលចាស់

ច្បាប់ចម្លងត្រឹមត្រូវតាមច្បាប់ដើម
ខេត្តកណ្តាល ថ្ងៃទី ១៤ ខែ ៦ ឆ្នាំ២០២០
ក្រឡាបញ្ជី
[redacted]

តែសកម្មភាពនេះ ខ្លួន និងប្រពន្ធ ឈប់ប្រព្រឹត្ត បានប្រហែលមួយខែទៅហើយ ដោយរវល់ហៅភ្ញៀវការ និងខ្លាចសមត្ថកិច្ចចាប់ខ្លួន។

៣-ជនជាប់ចោទឈ្មោះ [redacted] **សំអឿន** បានឆ្លើយថាៈ ប្ដីរបស់ខ្លួនឈ្មោះ [redacted] **សុភ័ក្ត្រ** គាត់ពីមុនធ្លាប់ជួញដូរគ្រឿងញៀន តែឥលូវគាត់ឈប់លក់គ្រឿងញៀនហើយ ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀន។ កន្លងមកខ្លួនធ្លាប់ទិញគ្រឿងញៀនពីឈ្មោះ រី ភេទប្រុស អាយុ ២៧ ឆ្នាំ យកមកវែលែកជាកញ្ចប់តូចៗ ដើម្បីលក់បន្ត ដោយឈ្មោះ រី បានប្រើឲ្យឈ្មោះ [redacted] ផាតសោភ័ណ្ឌ យកមកឲ្យខ្លួន។ លុះដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ ខ្លួនបានទៅហៅភ្ញៀវការនៅភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល។ ពេលទៅដល់ ស្រាប់តែឃើញសមត្ថកិច្ចឃាត់ប្ដីរបស់ខ្លួនឈ្មោះ [redacted] សុភ័ក្ត្រ ខ្លួនក៏បានចូលទៅសួរនាំ ស្រាប់តែសមត្ថកិច្ចឃាត់ខ្លួនតែម្ដង។ បន្ទាប់មកសមត្ថកិច្ចបានចុះទៅឆែកឆេរនៅផ្ទះរបស់ខ្លួនឃើញគ្រឿងញៀនចំនួន ០១ កញ្ចប់ធំ និងឧបករណ៍ប្រើប្រាស់វេចខ្ចប់មួយចំនួន ហើយក៏បន្តរុករកឃើញថ្នាំញៀនចំនួន ១០ កញ្ចប់ទៀត។

៤-ជនជាប់ចោទឈ្មោះ [redacted] **ផាតសោភ័ណ្ឌ** បានឆ្លើយថាៈ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ ប្រហែលម៉ោង១២ ថ្ងៃត្រង់ ខ្លួនបានចេញពីធ្វើការវិញ ខ្លួនបានទៅទិញថ្នាំពីឈ្មោះ វីត ហៅ រី ភេទប្រុស អាយុប្រហែល ២០ ឆ្នាំជាង នៅភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល បានចំនួន០៤ កញ្ចប់តូច តម្លៃ ៦០,០០០ រៀល ដើម្បីយកប្រើប្រាស់(ជក់) ជាមួយឈ្មោះ [redacted] ជេម និងពីរនាក់ទៀតមិនស្គាល់ឈ្មោះ លុយ៦០,០០០រៀល ទៀត ខ្លួនបានមកពីការរៃលុយគ្នាដោយឈ្មោះ វិចិត្រ ជេម ឲ្យខ្លួនបាន ១០,០០០ រៀល ហើយគេមិនបានទិញគ្រឿងញៀនជាមួយខ្លួនទេ។ នៅពេលដែលខ្លួនទិញថ្នាំញៀនពីឈ្មោះ វីត ហៅ រី បានហើយខ្លួនបានត្រលប់មកផ្ទះវិញ បានពាក់កណ្ដាលផ្លូវក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនបានតែម្ដង។ នៅពេលដែលសមត្ថកិច្ចឃាត់ខ្លួនបានដកហូតយកគ្រឿងញៀន ចំនួន០៤ កញ្ចប់តូច ក្រៅពីនោះពុំមានអ្វីទៀតទេ។ ខ្លួនធ្លាប់បានប្រើប្រាស់គ្រឿងញៀនចំនួន៥ ខែមកហើយ។

៥-ជនជាប់ចោទឈ្មោះ [redacted] **សំណាន** បានឆ្លើយថាៈ កន្លងមកខ្លួនធ្លាប់បានជាប់ពន្ធនាគាររយៈពេល ០១ឆ្នាំ ០១ខែ ពីបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅពន្ធនាគារខេត្តកណ្ដាល។ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល១១ ថ្ងៃត្រង់ ខ្លួនបានដេកលើអង្រឹងនៅផ្ទះចាប់ហួយ ស្រាប់តែសមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្ដង ហើយធ្វើការឆែកឆេរលើខ្លួន ពុំបានរកឃើញថ្នាំញៀនឡើយ ហើយក៏មិនបានដកហូតអ្វីពីខ្លួននោះទេ។ ខ្លួនធ្លាប់បានប្រើប្រាស់ថ្នាំញៀនរយៈពេលជាង ០២ ឆ្នាំមកហើយ ។ ថ្នាំដែលខ្លួនបានទិញមកប្រើប្រាស់នោះទិញពីឈ្មោះ [redacted] សុភ័ក្ត្រ ភេទប្រុស នៅភូមិលេខ១ ស្រុកស្អាង ខេត្តកណ្ដាល ដោយទិញម្ដង ០១ កញ្ចប់ តម្លៃ១៥,០០០ រៀល ទៅ ២០,០០០ រៀល។

៦-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ជេម** បានឆ្លើយថាៈ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង១០ និង៣០ នាទីព្រឹក ខ្លួនបានជិះកង់ចេញពីផ្ទះរបស់ខ្លួនតែម្នាក់ឯងនៅភូមិព្រែកសំរោង២ សង្កាត់ព្រែកសំរោង២ ទៅរកទិញថ្នាំញៀន ដើម្បីយកមកប្រើប្រាស់(ជក់) លុះទៅដល់ភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល ក៏បានជួបនិងឈ្មោះ **ភ័ណ្ឌ** ហើយឈ្មោះ **ភ័ណ្ឌ** ក៏បានបបួលខ្លួនថាចូលលុយគ្នាទិញថ្នាំមកជក់ ខ្លួនក៏បានឲ្យលុយទៅឈ្មោះ ភ័ណ្ឌ ១ម៉ឺនរៀល ដើម្បីឲ្យគាត់ទៅទិញថ្នាំញៀនជាមួយគ្នា ហើយឈ្មោះ **ភ័ណ្ឌ** ក៏បានទៅទិញថ្នាំញៀនតែម្នាក់ឯង ចំណែកឯខ្លួនរង់ចាំឈ្មោះ **ភ័ណ្ឌ** នៅមុខរោងចក្រ ប៉ាត់តេ ភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល បានមួយសន្ទុះក៏បានឃើញសមត្ថកិច្ចចាប់បណ្ដើរឈ្មោះ **ភ័ណ្ឌ** មករកខ្លួនដែលកំពុងរង់ចាំ ហើយសមត្ថកិច្ចបាន

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ខេត្តកណ្ដាល ថ្ងៃទី..16..ខែ..មិថុនា..ឆ្នាំ២០២០..
ក្រឡាបញ្ជី
[redacted]



Scanned with CamScanner

ចាប់រូបខ្លួនថែមមួយនាក់ទៀត ដោយធ្វើការឆែកឆេរមកលើរូបខ្លួនតែរកពុំឃើញមានថ្នាំញៀននោះទេ។ នៅពេលដែលសមត្ថកិច្ចចាប់រូបខ្លួននោះ គឺខ្លួននៅតែម្នាក់ឯងនោះទេ ពុំមានបក្សពួកផ្សេងទៀតនៅជាមួយខ្លួនទេ។ ខ្លួនពុំបានដឹងថាមានឈ្មោះ ភ័ណ្ឌ ទៅទិញថ្នាំញៀនប៉ុន្មានកញ្ចប់ទេ ព្រោះក្រោយពីឈ្មោះ ភ័ណ្ឌ ទិញថ្នាំញៀនរួចហើយ គាត់ពុំទាន់បានមកជួបខ្លួនផង ក៏ត្រូវបានសមត្ថកិច្ចចាប់បានខ្លួនគាត់បានតែម្តង។ នៅពេលសមត្ថកិច្ចចាប់ខ្លួនបានគឺមិនបានដកហូតសម្ភារៈអ្វីពីខ្លួនទេ។ ខ្លួនធ្លាប់បានប្រើប្រាស់គ្រឿងញៀនរយៈពេលប្រហែល១ឆ្នាំហើយមួយខែខ្លួនប្រើប្រាស់១ដង ខ្លួនពុំដែលធ្វើការជួញដូរថ្នាំញៀននោះទេ។

៧.តាមលទ្ធផលកោសលវិច័យលេខៈ **១៩៨១៦** /១៩ ម.ព.អ.ជ.ប.គ.៣ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ បានធ្វើការសេន្និដ្ឋានថាៈ វិជ្ជមាន, វត្ថុមានសារធាតុញៀន សំណាកជាគ្រឿងញៀនប្រភេទជាក្រាមម្សៅ ឈ្មោះ មេតំហ្វេតាមីន (ហៅ ក្រៅ អាយ ឬម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ៧៩,២២% នៃទម្ងន់សរុប ៥,៧២ ក្រាម វាស្ថិតនៅក្នុងតារាងទី ២ មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀន។ ដើម្បីផ្តន្ទាទោសកំណត់ពីទណ្ឌកម្មឲ្យបានត្រឹមត្រូវតាមច្បាប់ គប្បីគណនារកសារធាតុញៀន (៥,៧២ x៧៩,២២) ៖ ១០០ ដូច្នេះ បរិមាណធាតុសុទ្ធសរុប គឺ ៤,៥៣ ក្រាម ដូច្នេះបទល្មើសនេះ ជាបទមជ្ឈិម។

៨.តាមចម្លើយជនជាប់ចោទ, របាយការណ៍សំយោគ, សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ និងតាមឯកសារជាភស្តុតាងនានាក្នុងសំណុំរឿង ឃើញថា មានលក្ខណៈស៊ីសង្វាក់គ្នាយ៉ាងខ្លាំង ដែលអាចបញ្ជាក់បានថា កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ្ត,ឈ្មោះ [redacted] ផាត **សោភ័ណ្ឌ**, ឈ្មោះ [redacted] **សំអឿន** និងឈ្មោះ [redacted] **សំណាន** ពិតជាបានធ្វើសកម្មភាពប្រព្រឹត្តអំពើ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន(មិនរាងចាល)** និងឈ្មោះ [redacted] **ជេម** បានធ្វើសកម្មភាព ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ប្រាកដមែន។

៩.ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ្ត,ឈ្មោះ [redacted] ផាតសោភ័ណ្ឌ, ឈ្មោះ [redacted] សំអឿន ឈ្មោះ [redacted] **សំណាន** និងឈ្មោះ [redacted] ជេម មានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើស ជាក់ស្តែង កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង ១១: ៣០ នាទី ស្ថិតនៅភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល សមត្ថកិច្ចបានចុះបង្ក្រាបករណីជួញដូរគ្រឿងញៀន ដោយឃាត់ខ្លួនបានឈ្មោះ [redacted] សុភ័ក្រ្ត និងប្រពន្ធឈ្មោះ [redacted] **សំអឿន**, ឈ្មោះ [redacted] **ផាតសោភ័ណ្ឌ**, ឈ្មោះ [redacted] **សំណាន** និងឈ្មោះ [redacted] **ជេម** ដោយបានឆែកឆេររកថ្នាំញៀនចំនួន ១៥ កញ្ចប់ (២ធំ តូច១៣កញ្ចប់) និងសម្ភារៈសម្រាប់វេចខ្ចប់គ្រឿងញៀនមួយចំនួនទៀត។

១០.ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ្ត,ឈ្មោះ [redacted] ផាតសោភ័ណ្ឌ, ឈ្មោះ [redacted] សំអឿន,ឈ្មោះ [redacted] **សំណាន** និងឈ្មោះ [redacted] **ជេម** ជាសមត្ថជនមានស្មារតីល្អគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ នូវរាល់អំពើដែលខ្លួនបានប្រព្រឹត្តចំពោះមុខច្បាប់ ។

១១.អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ្ត,ឈ្មោះ [redacted] ផាតសោភ័ណ្ឌ, ឈ្មោះ [redacted] **សំអឿន**,ឈ្មោះ [redacted] **សំណាន** និងឈ្មោះ [redacted] **ជេម** បានធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម ហើយអំពើនេះរដ្ឋកំពុងយកចិត្តទុកដាក់បង្ក្រាបយ៉ាងសកម្ម និងកំណត់ទុកថាជាបទល្មើសព្រហ្មទណ្ឌត្រូវផ្តន្ទាទោស។

១២.មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] សុភ័ក្រ្ត, ឈ្មោះ [redacted] ផាត **សោភ័ណ្ឌ**,ឈ្មោះ [redacted] **សំអឿន** និងឈ្មោះ [redacted] **សំណាន** ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន



បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ខេត្តកណ្ដាល ថ្ងៃទី...១៦...ខែ..៦..ឆ្នាំ២០២០
ក្រឡាបញ្ជី
Sahw
[redacted]

និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន(មិនរាងចាល) ប្រព្រឹត្តនៅភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ ,៤៥ **កថាខណ្ឌ២** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និងឈ្មោះ [redacted] **ជេម** ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **៤៥ កថាខណ្ឌ១** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

១៣.វត្ថុចាប់យករួមមានៈ

-សំណាកជាគ្រឿងញៀនប្រភេទមេតំហ្វេតាមីនចំនួន ១៥ កញ្ចប់ ទម្ងន់ ៥,៧២ ក្រាម។

-ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន ០១ ពណ៌ខ្មៅ។

-ម៉ូតូចំនួន០២ គ្រឿង មានៈ

+ម៉ាក HONDA C125 ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1BU-6457 និងកូនសោចំនួន ០១ គ្រឿង។

+ម៉ាក ពូហ្សា ពណ៌ខ្មៅ គ្មានស្លាកលេខចំនួន ០១ គ្រឿង។

-សម្ភារៈសម្រាប់វេចខ្ចប់ និងសម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួន។

**តុលាការគប្បីរំលឹកសម ។**

១៤.ជនជាប់ចោទឈ្មោះ [redacted] **សំណាន** ភេទប្រុស អាយុ១៧ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] **ជេម** ភេទប្រុស អាយុ ១៧ ជាអនីតិជន គប្បីតុលាការសម្រេច និងប្រកាសទោសដែលត្រូវអនុវត្តចំពោះអនីតិជន តាមមាត្រា **១៦០** នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

១៥-ជនជាប់ចោទឈ្មោះ [redacted] **ជេម** មិនធ្លាប់មានប្រវត្តិនៃការផ្ដន្ទាទោសពីមុនមក ទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង បទល្មើសដែលជននេះប្រព្រឹត្តជាបទមជ្ឈិម គប្បីតុលាការសម្រេចផ្ដល់ការព្យួរទោសដល់ជនជាប់ចោទ តាមមាត្រា**១០៧** និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

**១- ផ្ដន្ទាទោស ៖**

ក.ជនជាប់ចោទឈ្មោះ [redacted] **សុភ័ក្ត្រ** ភេទប្រុស អាយុ ៣៣ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០(បួនលាន) រៀល។

ខ.ជនជាប់ចោទឈ្មោះ [redacted] **ផាតសោភ័ណ្ឌ** ភេទប្រុស អាយុ ២៦ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០(បួនលាន) រៀល។

គ.ជនជាប់ចោទឈ្មោះ [redacted]**ប់អឿន** ភេទស្រី អាយុ ២៩ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) រៀល។

ឃ.ជនជាប់ចោទឈ្មោះ [redacted] **សំណាន** ភេទប្រុស អាយុ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២.០០០.០០០(ពីរលាន)រៀល។

ពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា៤៥ **កថាខណ្ឌ២** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។



ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ខេត្តកណ្ដាល ថ្ងៃទី ១៦ ខែ ៦ ឆ្នាំ២០២០

ក្រឡាបញ្ជី

[redacted]

Scanned with CamScanner

ង.ជនជាប់ចោទឈ្មោះ [redacted] ជេម ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ខែ តែទោសអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេល **០១(មួយ)ខែ និង ១៩(ដប់ប្រាំបួន)ថ្ងៃ** ទោសនៅសល់ពីនេះត្រូវព្យួរធម្មតា និងពិន័យជាប្រាក់ចំនួន **១០០.០០០** (មួយសែន)រៀល។

ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **៤៥ កថាខណ្ឌ១** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**២-វត្ថុតាងរឹបអូសមានៈ**

-សំណាកជាគ្រឿងញៀនប្រភេទមេតំហ្វេតាមីនចំនួន ១៥ កញ្ចប់ ទម្ងន់ ៥,៧២ ក្រាម។

-ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន ០១ ពណ៌ខ្មៅ។

-ម៉ូតូចំនួន០២ គ្រឿង មានៈ

+ម៉ាក HONDA C125 ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1BU-6457 និងកូនសោចំនួន ០១ គ្រឿង។

+ម៉ាក ពូហ្សា(ចាស់បិទស្កុតខ្មៅ គ្មានស្លាកលេខចំនួន ០១ គ្រឿង។

-សម្ភារៈសម្រាប់វេចខ្ចប់ និងសម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួន។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ្ត, ឈ្មោះ [redacted] សំអឿន, ឈ្មោះ [redacted] ផាតសោភ័ណ្ឌ ,ឈ្មោះ [redacted] សំណាន និង កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ជេម និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។

រក្សាសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា |

[redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃព្រហស្បតិ៍ ៦កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

កណ្ដាល, ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០

**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ខេត្តកណ្ដាល,ថ្ងៃទី...១៦...ខែ..០៦..ឆ្នាំ២០២០..

ក្រឡាបញ្ជី

[redacted]